ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១១៦៤
ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០១៨

សាលដីកា
លេខ: ៤០ ក្រVI "ប.ស"
ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើ តាមព្រះរាជក្រមលេខ: នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦-៧-២០១៤ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២១ ដែលមានសមាសភាពដូចខាងក្រោម៖

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

## ក្រឡាបញ្ជីសវនាការ

លោក [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១១៦៤ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលមាន:

-ជនជាប់ចោទឈ្មោះ [redacted] ហេង ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើត: ភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បច្ចុប្បន្ន: [redacted] ឆែប ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] នៅលើរ ទោសពីមុនគ្មាន ។

(ឃុំខ្លួននៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៨ នៅពន្ធនាគារខេត្តព្រះវិហារ)

**ជាប់ចោទពីបទ:** រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស ដោយសារមូលហេតុអាយុជនរងគ្រោះ ប្រព្រឹត្តនៅភូមិក្តុល ឃុំម្លូព្រៃ ស្រុកឆែប ខេត្តព្រះវិហារ កាលពីថ្ងៃទី ១៦-៣-ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៤១ ចំណុច ១ នៃក្រមព្រហ្មទណ្ឌ ។





Scanned with CamScanner

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ៤៩ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិគុល ឃុំម្លូព្រៃ ស្រុកឆែប ខេត្តព្រះវិហារ បច្ចុប្បន្ន [redacted] ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] ប្ដីឈ្មោះ [redacted] មានកូន ០៧នាក់ ។

-ជនរងគ្រោះឈ្មោះ [redacted] ភេទស្រី អាយុ ១៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិគុល ឃុំម្លូព្រៃ ស្រុកឆែប ខេត្តព្រះវិហារ ។ [redacted] ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] នៅលីវ ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទ

កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ០៩ ^H ០០^នាទី យប់ ឈ្មោះ ឃី លេង បានចាប់រំលោភសេពសន្ថវៈលើក្មេងស្រីរងគ្រោះឈ្មោះ [redacted] ដោយពេលនោះម្ដាយឪពុករបស់ឈ្មោះ [redacted] មិននៅផ្ទះ គាត់បានចេញទៅចាប់កង្កែប ហើយឈ្មោះ [redacted] លេង គិតថាជាឱកាសល្អដោយមានតែពីរនាក់និងឈ្មោះ [redacted] ក្នុងពេលនោះឈ្មោះ [redacted] កំពុងបបរបាយជ្រូកនៅក្រោយផ្ទះ ពេលបបរបាយជ្រូករួចឈ្មោះ [redacted] ក៏បានឡើងមកលើផ្ទះស្រាប់តែឈ្មោះ [redacted] លេង មកចាប់អោបនាងពីក្រោយ រួចប្រឡេះខ្សៀវខោនាង ស្រាតខោ និងផ្ដួលនាងទៅលើក្ដារួចយកដៃសង្កត់ទ្រូងនាង និងបានយកលិង្គមកដាក់បញ្ចូលក្នុងប្រដាប់ភេទរបស់នាង ប៉ុន្មាននាទីក្រោយមកឈ្មោះ [redacted] លេង បានក្រោកពីនាង ហើយដើរមកដេកវិញ ។ លើកទី២ នៅថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៧ វេលាម៉ោងប្រហែល ១១ព្រឹក ពេលនោះនាងកំពុងដេកស្រាប់តែឈ្មោះ [redacted] លេង បានចូលក្នុងបន្ទប់របស់នាង ហើយចាប់សម្រាតខោក្នុង និងបានសើយសំពតនាងរំលោភបានសម្រេច ។ លើកទី៣ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០១៧ វេលាម៉ោង ១ថ្ងៃត្រង់ នាងកំពុងស្លៀកពាក់បម្រុងងូតទឹកស្រាប់តែឈ្មោះ [redacted] លេង ចូលទៅអោប ហើយផ្ដួលនាងទៅលើកន្ទេលរួចធ្វើសកម្មភាពបានសម្រេច ។ ក្រោយមកម្ដាយជនរងគ្រោះដឹងរឿង និងបានដាក់ពាក្យបណ្ដឹងទៅសមត្ថកិច្ច ហើយសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកតុលាការតែម្ដង ។

15ឆ្នាំ

-រឿងនេះសាលាដំបូងខេត្តព្រះវិហារ បានសម្រេចសេចក្ដី តាមអំណាចសាលក្រមព្រហ្មទណ្ឌលេខៈ ៣៦ "ឃ" ចុះថ្ងៃទី ២៨-៨-២០១៨ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ [redacted] លេង ភេទប្រុស អាយុ ៣៦ឆ្នាំ ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ៨ឆ្នាំ (ប្រាំបី) ពីបទៈ រំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសដោយសារមូលហេតុអាយុជនរងគ្រោះ) ប្រព្រឹត្តនៅភូមិគុល ឃុំម្លូព្រៃ ស្រុកឆែប ខេត្តព្រះវិហារ កាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសតាមបញ្ញត្តិ



Scanned with CamScanner

មាត្រា ២៤១ ចំណុច ១ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យឈ្មោះ [redacted] លេង សងសំណងការខូចខាត និងជម្ងឺចិត្តទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] និងជនរងគ្រោះឈ្មោ [redacted] ចំនួន ៤.០០០.០០០៛ ( បួនលានរៀល) ការទាមទារលើសពីនេះត្រូវច្រានចោល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១០-៨-២០១៨ ចំពោះមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ចំពោះមុខជនរងគ្រោះ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៨-៨-២០១៨ ។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខៈ ២៣ ចុះថ្ងៃទី២៨-៨-២០១៨ របស់ពិរុទ្ធជនឈ្មោះ ឃី លេង ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ៣៦ "យ" ចុះថ្ងៃទី២៨-៨-២០១៨ របស់សាលាដំបូងខេត្តព្រះវិហារ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ របាយការណ៍សង្ខេបអង្គហេតុចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៨ ។

-បានឃើញ សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] លេង (វត្តមាន)

-មេធាវី: កញ្ញា [redacted] (វត្តមាន)

-មេធាវី: លោក [redacted] (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] (វត្តមាន)

-ជនរងគ្រោះឈ្មោះ [redacted] (វត្តមាន)

-មេធាវី: លោកស្រី [redacted] (វត្តមាន)

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបអង្គហេតុ:

-ជនជាប់ចោទឈ្មោះ [redacted] លេង បានឆ្លើយបញ្ជាក់ថា: ខ្លួនមករស់នៅផ្ទះ [redacted] បាននេះរយៈពេល ២ខែ ក្រោយមកបានឱ្យខ្ញុំយក [redacted] ។ ( ឪពុក-ម្តាយនាង )

-ខ្លួនមិនដែលធ្លាប់ស្រលាញ់ឈ្មោះ [redacted] ទេ ហើយឈ្មោះ [redacted] គាត់ខ្លាចតែបងប្រុសគាត់ទេ ជាពិសេស បងប្រុសរបស់គាត់ដែលធ្លាប់វៃឪពុករបស់គាត់ ហេតុនេះហើយទើបគាត់ខ្លាចបងប្រុសនេះណាស់ ។ ក្រោយពេលខ្ញុំបានដឹងរឿងរបស់នាង [redacted] ។ ពេលដែលខ្ញុំទៅនៅផ្ទះ [redacted] គាត់មានបងប្រុសម្នាក់ និងប្អូនប្រុសម្នាក់។ បងប្រុសឈ្មោះ [redacted] ចេញ-ចូលក្នុងផ្ទះ



Scanned with CamScanner

ហើយគាត់មិនដែលត្រូវរ៉ូវជាមួយឪពុកម្តាយរបស់គាត់ទេ ។ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ តាមពិតបងប្រុសរបស់គាត់ចាប់រំលោភ។ ពេលនោះខ្លួនទៅប្រាប់អ៊ុំរបស់គាត់ ដែលរស់នៅកន្លែងនោះ ហើយគាត់បានប្រាប់ខ្លួនថា បងរបស់គាត់ "បងទី១" ចាប់រំលោភគាត់ ។ ខ្លួនជាជាងចម្លាក់នៅទីនោះ។ ថ្ងៃរើកង្កែបនោះខ្លួននៅទីនោះមែន តែមិនបានរំលោភនាងទេ។

-ជនរងគ្រោះឈ្មោះ [redacted] បានឆ្លើយថា: បន្ទប់បងប្រុសខ្លួននៅជិតគ្នា ខ្លួនមិនធ្លាប់មានទាក់ទំនងជាមួយគាត់ទេ ។ ថ្ងៃកើតហេតុឈ្មោះ [redacted]ឈេង បានរួមភេទជាមួយខ្លួន ៣ដង ពេលរួមភេទរួចហើយគាត់បានប្រាប់ថា កុំប្រាប់ម៉ែឪ ។ គាត់បានឡើងមកចាប់ខ្លួនពីក្រោយនៅពេលឪពុកម្តាយខ្លួនទៅចាប់កង្កែប គាត់ចាប់ដៃម្ខាង ហើយដៃម្ខាងទៀតស្រាតខោខ្លួន ហើយនៅពេលថ្ងៃម្តងទៀតនៅក្នុងបន្ទប់ ក្រោយពីរួមភេទហើយ ខ្លួននិងគាត់មិនដែលនិយាយរកគ្នាទេ ។ចំពោះបងប្រុសខ្លួនគាត់ធ្លាប់ចូលបន្ទប់ខ្លួន គឺចូលមកសុំលុយ ហើយកូននេះជាកូនខ្ញុំជាមួយប្តីខ្ញុំ ក្រោយពេលឈ្មោះ [redacted]ឈេង រំលោភ ។ លើកទី៣ ប្រហែល ម៉ោង ១១ ថ្ងៃត្រង់ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុំឱ្យតុលាការរកយុត្តិធម៌ និងទាមទារសំណង ៣.០០០$ (បីពាន់ដុល្លារអាមេរិក) ។

## សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងដែលមានការពាក់ពន្ធ័ក្នុងសំណុំរឿងរួចមកឃើញថា ទ្រង់តាមការសួរដេញដោលនៅពេលនេះ រួចទាំងចម្លើយក្នុងកំណត់ហេតុឃើញថាចម្លើយនិងមានភស្តុតាងនេះមានលក្ខណៈស៊ីសង្វាក់ជាមួយចម្លើយជនរងគ្រោះ។

-តំណាងមហាអយ្យការយល់ឃើញថាសេចក្តីសម្រេចនៃសាលក្រមមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតម្កល់សាលក្រមទុកជាបានការ ។

## សេចក្តីសន្និដ្ឋានមេធាវីការពារជនរងគ្រោះ

*-មេធាវី:* លោកស្រី [redacted]ន ជាមេធាវីការពារជនរងគ្រោះឈ្មោះ [redacted] បានសន្និដ្ឋានថា: ការឆ្លើយដោះសាររបស់ជនជាប់ចោទពុំមានគួរឱ្យជឿបានទេ ។ តាមអង្គហេតុនេះឃើញថាជនរងគ្រោះពិតជាបានទទួលរង នូវការរំលោភពីសំណាក់ជនជាប់ចោទពិតមែន ។

*សំណូមពរ:* សុំតម្កល់សាលក្រមទុកជាបានការពេញទាំងមូល ។

## សេចក្តីសន្និដ្ឋានមេធាវីការពារជនជាប់ចោទ

*-មេធាវី:* លោក [redacted]ថ្មី និង [redacted]ម៉ូនីកា ជាមេធាវីការពារជនជាប់ចោទឈ្មោះ [redacted]ឈេង បាន



Scanned with CamScanner

សន្និដ្ឋានថា: សំអាងហេតុដែលសាលាដំបូងបានលើកយកមកផ្តន្ទាទោសកូនក្តីខ្ញុំឈ្មោះ [redacted] ពេង ពីបទ: រំលោភសេពសន្ថវៈនេះគឺផ្អែកតែលើចម្លើយរបស់ភាគីជនរងគ្រោះតែម្ខាងតែប៉ុណ្ណោះ ។ នៅពេលតុលាការបានចោទប្រកាន់មកលើឈ្មោះ [redacted] ពេង ,ជនរងគ្រោះឈ្មោះ [redacted] មានអាយុ១៧ឆ្នាំទៅហើយ មានកាយសម្បទាល្អ ថែមទាំងមានស្មារតីល្អទៀត ហេតុអ្វីបានមិនស្រែកឱ្យគេជួយ និងមានបន្ទប់បងប្រុសនៅជិតនោះ។ តាមអង្គហេតុនេះឃើញថាការចោទប្រកាន់ និងការសម្រេចផ្តន្ទាទោស គឺមិនត្រឹមត្រូវទេ ។នេះគ្រាន់តែជាការសង្ស័យប៉ុណ្ណោះយោងតាមមាត្រា ៣៨ កថាខណ្ឌ ៩ នៃរដ្ឋនៃរដ្ឋធម្មនុញ្ញចែងថា "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ" ។

*សំណូមពរ:* សុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចឲ្យកូនក្តីខ្ញុំឈ្មោះ [redacted] ពេង រួចផុតពីបទចោទប្រកាន់ និងសម្រេចដោះលែងឱ្យមានសេរីភាពវិញ ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍សង្ខេបអង្គហេតុ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារជនចាប់ចោទ

-ក្រោយពីបានពិនិត្យកស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាពិចារណាត្រឹមត្រូវតាមច្បាប់

## **<u>សាលាឧទ្ធរណ៍</u>**
## **<u>យល់ឃើញថា</u>**

១-ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ: ២៣ ចុះថ្ងៃទី២៨-៨-២០១៨ របស់ពិរុទ្ធជនឈ្មោះ [redacted] ពេង ប្តឹងឧទ្ធរណ៍និងសាលក្រមព្រហ្មទណ្ឌលេខ: ៣៦ "ឃ" ចុះថ្ងៃទី ២៨-៨-២០១៨ ត្រង់ចំណុចសេចក្តីសម្រេចធ្វើឡើងក្នុងកំណត់ច្បាប់សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងតាមមាត្រា ៣៨២ ច្បាប់វិសោធនកម្ម នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ពេង បានឆ្លើយបញ្ជាក់ថា ខ្លួនមិនបានរំលោភលើជនរងគ្រោះទេ តែខ្លួនបានសួរជនរងគ្រោះ ពេលឃើញបងប្រុសនាង ចេញចូលបន្ទប់ជន



Scanned with CamScanner

រងគ្រោះ។ខ្លួនជាជាងចម្លាក់នៅផ្ទះឪពុកម្ដាយរបស់ជនរងគ្រោះ ខ្លួនធ្លាប់ឈ្លោះបងប្រុសជនរងគ្រោះដែលបានវាយឪពុករបស់ខ្លួន ហើយឈ្មោះ [redacted] នេះក៏បានដេញខ្លួនចេញពីផ្ទះនោះ។ ក្រោយមក ១០ថ្ងៃ ទើបគេប្ដឹង ។ ជនរងគ្រោះធ្លាប់ប្រាប់ថា បងប្រុសរបស់នាងជាអ្នករំលោភ នៅវាលស្រែ ហើយខ្លួនបានប្រាប់អ៊ុំស្រីរបស់ជនរងគ្រោះផងដែរ ។

៣-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] បានបញ្ជាក់ថា ជនជាប់ចោទបានចាប់រំលោភខ្លួនចំនួន ៣ដង ។ ពេលរំលោភនោះខ្លួនមិនបានស្រែកឱ្យគេជួយទេ ព្រោះដោយសារភ័យពេក ។ ក្រោយរំលោភបាន ៣ដង គាត់សន្យាថា ដណ្ដឹងខ្លួនធ្វើជាប្រពន្ធ ។ បងប្រុសខ្លួនស្ដីបន្ទោសឱ្យជនជាប់ចោទ ក៏បានឈ្លោះជាមួយគ្នា ហើយបងប្រុសដេញជនជាប់ចោទមិនឱ្យនៅផ្ទះជាមួយទៀត ។

៤-តាមសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការបានបញ្ជាក់ថា បណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទមានលក្ខណៈ ត្រឹមត្រូវតាមទម្រង់ច្បាប់ ហើយមានភស្តុតាងស៊ីសង្វាក់ជាមួយចម្លើយជនរងគ្រោះ ។ សេចក្ដីសម្រេចនៃសាលក្រមមានលក្ខណៈត្រឹមត្រូវតាមច្បាប់ សុំតម្កល់សាលក្រមទុកជាបានការ ។

៥-តាមសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនរងគ្រោះបានបញ្ជាក់ថា ជនរងគ្រោះបានទទួលរង នូវការរំលោភ តែជនជាប់ចោទមិនបានសារភាពទេ តែតាមចម្លើយរបស់ជនជាប់ចោទ ជាភស្តុតាងបញ្ជាក់ជាមួយកោសល្យវិច័យ ដែលបញ្ជាក់ពីពិរុទ្ធភាពលើជនជាប់ចោទ ហេតុនេះសុំឱ្យតុលាការតម្កល់សាលក្រមទុកជាបានការ ។

៦-តាមសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទបានបញ្ជាក់ថា គ្រាន់តែជាការសង្ស័យតែប៉ុណ្ណោះ ជនរងគ្រោះអះអាងថា មានការរំលោភ តែមិនស្រែកឱ្យគេជួយទេ ហើយបន្ទប់ជនរងគ្រោះជាប់បន្ទប់បងប្រុស បែរជាពុំមានអ្នកដឹង បងប្រុសរបស់ជនរងគ្រោះធ្លាប់ឈ្លោះទាស់ទែងជាមួយជនជាប់ចោទ ហើយកោសល្យវិច័យធ្វើក្រោយកើតហេតុ ៣ខែ ពុំមានភស្តុតាងណាបញ្ជាក់ ក្រៅពីចម្លើយជនរងគ្រោះទេ ហេតុនេះ សុំឱ្យតុលាការសម្រេចឱ្យជនជាប់ចោទរួចផុតពីបទចោទ ។

៧-យល់ឃើញថា តំណាងមហាអយ្យការបានសន្និដ្ឋានបញ្ជាក់ថា មានភស្តុតាងស៊ីសង្វាក់ ហើយចម្លើយជនរងគ្រោះដែលបានបញ្ជាក់ រួមជាមួយកោសល្យវិច័យ ទីតាំងប្រព្រឹត្តក្នុងដំណាក់កាលនីមួយៗឃើញថា មានភាពស៊ីសង្វាក់ដែលអាចកំណត់បានថា ជនជាប់ចោទប្រព្រឹត្តអំពើរំលោភលើជនរងគ្រោះ ដូចសាលក្រមរបស់សាលាដំបូងបានសម្រេច ។

៨-តុលាការសាលាដំបូងខេត្តព្រះវិហារ បានលើកយកសំអាងហេតុ បញ្ជាក់មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដោយពុំចាំបាច់សរសេរសំអាងហេតុដដែលនោះបញ្ជាក់សារជាថ្មីទៀតទេ ។

សេចក្ដីសម្រេចនៃសាលក្រមលេខ:៣៦-យ- ចុះថ្ងៃទី ២៨-៨-២០១៨ មានលក្ខណៈត្រឹម



Scanned with CamScanner

ត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការដដែល ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខៈ២៣ ចុះថ្ងៃទី ២៨-៨-២០១៨ របស់ពិរុទ្ធជនឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយទាស់ និងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ៣៦ "ឃ" ចុះថ្ងៃទី ២៨-៨-២០១៨ របស់សាលាដំបូងខេត្តព្រះវិហារ ទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១០-០២-២០២១ កំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចំពោះមុខឈ្មោះ [redacted] ប្រកាសជាសាធារណៈនៅថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២១ ។

-បើកសិទ្ធិប្តឹងសារទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| លោក [redacted] | លោកស្រី [redacted] | លោក [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner